# ការប្រើប្រាស់ឯកសារនេះ

## គោលបំណង

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះផ្តល់នូវការណែនាំ និងជាឧបករណ៍មួយក្នុងការរៀបចំវគ្គបណ្តុះបណ្តាលពេញលេញមួយលើការប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ។ វាត្រូវបានបង្កើតឡើងសម្រាប់គ្រូបង្គោល និងបុគ្គលិករដ្ឋ និងបុគ្គលិកកម្មវិធីថែទាំ និងគាំទ្រដល់អ្នករស់នៅជាមួយមេរោគអេដស៍។ អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះគួរមានទាំងបុគ្គលិកដែលបម្រើការនៅសេវាសុខភាពកម្រិតមូលដ្ឋាន នៅសហគមន៍ និងនៅតាមផ្ទះរបស់អ្នករស់នៅជាមួយមេរោគអេដស៍។ ប្រាកដណាស់ឯកសារនេះត្រូវបានបង្កើតឡើងសម្រាប់សមាជិកក្រុមថែទាំតាមផ្ទះ ឬអ្នកផ្តល់ប្រឹក្សា ប៉ុន្តែយើងមិនកំណត់តែត្រឹមហ្នឹងទេ។ គេក៏អាចយកកញ្ចប់សម្ភារៈនេះទៅបណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាព បុគ្គលិកសេវាព្យាបាលជំងឺឱកាសនិយម/សេវាព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគអេដស៍ ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែរ។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងចំណេះដឹង និងជំនាញគាំទ្រ និងថែទាំដោយប្រើប្រាស់អាហារូបត្ថម្ភ ដល់អ្នកទាំងឡាយដែលមានតួនាទីផ្តល់ព័ត៌មានទូទៅអំពីអាហារូបត្ថម្ភ និងផ្តល់ការថែទាំគាំទ្រដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ជំនាញចាំបាច់ និងចំណេះដឹងក្នុងការផ្តល់ប្រឹក្សាដែលឆ្លើយតបទៅតាមតម្រូវការរបស់អតិថិជន។ វគ្គបណ្តុះបណ្តាលចាប់ផ្តើមដោយផ្តល់ព័ត៌មានមូលដ្ឋានអំពីអាហារូបត្ថម្ភ និងមេរោគអេដស៍ កសាងជំនាញក្នុងការវាស់វែងទិន្នន័យអំពីរាងកាយ និងបណ្តុះជំនាញផ្តល់ប្រឹក្សាជាមួយនឹងកញ្ចប់សម្ភារៈ។ ការផ្តល់ប្រឹក្សាត្រូវបានរៀបចំជាវិធីសាស្ត្រដែលមានប្រាំជំហាន ដែលមានបែងចែកច្បាស់នៅក្នុងទម្រង់តាមដាន ដែលផ្តល់ជាការណែនាំងាយស្រួលសម្រាប់អ្នកផ្តល់ប្រឹក្សាអនុវត្តតាម។ វគ្គបណ្តុះបណ្តាលនេះ បង្រៀនអំពីរបៀបវាយតម្លៃទៅសកម្មភាពរបស់អតិថិជនពាក់ព័ន្ធទៅនឹងរបបអាហារ និងការថែទាំសុខភាពរបស់ពួកគេ និងដើម្បីផ្តល់ការណែនាំយោងទៅតាមការវាយតម្លៃនេះ។ ប័ណ្ណរស់នៅប្រកបដោយសុខភាពល្អចំនួន២៥ មានបង្ហាញរូបភាពពណ៌ ដែលផ្តល់នូវសារគន្លឹះក្នុងការរក្សាសុខភាពឱ្យបានល្អ គ្រប់គ្រងរោគសញ្ញាជំងឺផ្សេងៗ និងជម្រុញការស្វែងរកសេវាថែទាំសុខភាពទាន់ពេល។ ប័ណ្ណជំនួយទាំងនេះគឺសម្រាប់ប្រើក្នុងពេលវេលាជាក់ស្តែងណាមួយ ទៅតាមអាទិភាពដែលបានកំណត់ក្នុងអំឡុងពេលផ្តល់ប្រឹក្សាដល់អតិថិជន។

ការបណ្តុះបណ្តាលនេះផ្តល់នូវឱកាសជាច្រើនដល់សិក្ខាកាមក្នុងការអនុវត្តន៍នូវជំនាញថ្មីក្នុងការផ្តល់ប្រឹក្សា និងបញ្ចប់ដោយការចុះអនុវត្តន៍ផ្ទាល់ជាមួយអតិថិជនជាក់ស្តែង។ គួរកត់សម្គាល់ថា ការផ្តល់ប្រឹក្សាមានប្រសិទ្ធភាពបំផុតគឺនៅពេលដែលមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងអ្នកផ្តល់ប្រឹក្សា និងអតិថិជន។ ការស្តាប់ ការយល់ ការបង្រៀន និងការផ្តល់ដំបូន្មានគឺមាននៅក្នុងកញ្ចប់សម្ភារៈអាហារល្អ។ អ្នកផ្តល់ប្រឹក្សាត្រូវបានជំរុញឱ្យផ្តល់យោបល់ពិភាក្សា និងចរចាជាមួយអតិថិជន អំពីជម្រើសក្នុងការលើកកម្ពស់របបអាហារ និងសុខភាព ដែលសមស្របបំផុតទៅតាមធនធានដែលពួកគាត់មាន។

កញ្ចប់សម្ភារៈ និងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលយកលំនាំតាមគោលការណ៍ណែនាំដែលអនុញ្ញាតឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ទទួលបានបទពិសោធន៍ និងកែប្រែវិធីរស់នៅរបស់ពួកគេឱ្យកាន់តែប្រសើរឡើង។ ចុងក្រោយនេះយើងអាចនិយាយបានថាកញ្ចប់សម្ភារៈអាហារល្អមិនគ្រាន់តែជាការណែនាំក្នុងការបរិភោគអាហារដោយមានសុខភាពល្អនោះទេ វាក៏ជាឧបករណ៍សម្រាប់ការសិក្សា ការផ្តល់ប្រឹក្សា ការដោះស្រាយបញ្ហា និងការផ្លាស់ប្តូរឥរិយាបថដែលនឹងជួយដល់អ្នកផ្តល់ប្រឹក្សាក្នុងកិច្ចគាំពារដល់អ្នករស់នៅជាមួយមេរោគអេដស៍ ដើម្បីកំណត់ និងស្វែងរកដំណោះស្រាយជាក់ស្តែងចំពោះបញ្ហាសុខភាព និងរបបអាហារដែលពួកគេជួបប្រទះប្រចាំថ្ងៃ។ នៅពេលដែលមានភាពស្ទាត់ជំនាញលើមូលដ្ឋានប្រើប្រាស់កញ្ចប់សម្ភារៈហើយ គ្រូបង្គោល និងអ្នកផ្តល់ប្រឹក្សាគួរស្វែងរកនូវវិធីថ្មីៗទៀតក្នុងការប្រើប្រាស់កញ្ចប់សម្ភារៈនេះ។ លទ្ធភាពដែលអាចធ្វើទៅបានគឺគ្មានដែនកំណត់ទេ។

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះត្រូវបានរៀបចំឡើងសម្រាប់អនុវត្តនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែវាប្រាកដជាមិនអាចរួមបញ្ចូលបានទាំងអស់នូវភាពខុសៗគ្នាតាមមូលដ្ឋាន ដែលមានបរិបទ វប្បធម៌ សាសនា និងសេដ្ឋកិច្ចសង្គមខុសៗគ្នានោះទេ។ ភាពខុសគ្នាក៏អាចកើតមានដោយសារប្រព័ន្ធសុខាភិបាល និងធនធានតាមមូលដ្ឋានមានភាពខុសគ្នាដែរ។ កម្រិតធនធានខុសគ្នា ជាពិសេសធនធានអាហារ ក៏បង្កឱ្យមានភាពខុសគ្នាទៅលើការគ្រប់គ្រងអាហារូបត្ថម្ភដែរ។ ភាពខុសប្លែកគ្នាទាំងនេះមានឥទ្ធិពលទៅលើការថែទាំ និងគាំទ្រផ្នែកអាហារូបត្ថម្ភ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ កុមារកំព្រា និងកុមារងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។ ដូច្នេះ វគ្គបណ្តុះបណ្តាលនេះត្រូវសម្របទៅតាមបរិបទមូលដ្ឋាន។ អ្នកសម្របសម្រួលអាចអញ្ជើញអ្នកមានបទពិសោធន៍បណ្តុះបណ្តាលឱ្យចូលរួមក្នុងវគ្គ ដើម្បីឱ្យពួកគេផ្តល់មតិកែលម្អក្នុងការកែប្រែកញ្ចប់សម្ភារៈឱ្យសមស្របទៅតាមតម្រូវការមូលដ្ឋាន ឧទាហរណ៍ ដកស្រង់ករណីសិក្សាចេញពីបទពិសោធន៍ជាក់ស្តែងក្នុងមូលដ្ឋាន។

## ព័ត៌មានសំខាន់សម្រាប់អ្នកសម្របសម្រួល

មេរៀននីមួយៗនៅក្នុងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះមានព័ត៌មានដូចខាងក្រោម៖

- ការរៀបចំសម្រាប់អ្នកសម្របសម្រួល៖ ពន្យល់ពីថេរវេលាប៉ាន់ស្មានរបស់មេរៀន សម្ភារៈដែលត្រូវការ និងវិធីសាស្ត្របង្រៀន។
- ជំហាននៃការណែនាំ៖ រួមបញ្ចូលទាំងការណែនាំរបស់មេរៀន គោលបំណងនៃមេរៀន និងការជំហានណែនាំពីរបៀបនៃសម្របសម្រួលដល់ការរៀនសូត្ររបស់សិក្ខាកាម។
- សំណួរសាកល្បង៖ នៅចុងបញ្ចប់នៃមេរៀននីមួយៗ មានសំណួរគន្លឹះមួយចំនួនដើម្បីវាយតម្លៃការសិក្សារបស់សិក្ខាកាម។ ចម្លើយត្រឹមត្រូវមាននៅចុងបញ្ចប់នៃសំណួរ។ ក្រៅពីសំណួរសាកល្បងសម្រាប់មេរៀន ក៏មានសំណួរសាកល្បងសម្រាប់មុន និងក្រោយវគ្គ (ឧបសម្ព័ន្ធទី១) សម្រាប់ធ្វើការវាយតម្លៃការយល់ដឹងរបស់សិក្ខាកាម មុន និងក្រោយពេលវគ្គបណ្តុះបណ្តាល។
- ទម្រង់វាយតម្លៃវគ្គប្រចាំថ្ងៃ(ឧបសម្ពន្ធ័ទី២) សម្រាប់សិក្ខាកាមបំពេញរាល់ថ្ងៃ ដើម្បីប្រមូលមតិកែលម្អអំពីការរៀបចំ ការសម្របសម្រួល ខ្លឹមសារវគ្គបណ្តុះបណ្តាល និងការអនុវត្តនូវចំណេះ និងជំនាញ។
- ទម្រង់វាយតម្លៃការចុះអនុវត្តន៍នៅមូលដ្ឋាន(ឧបសម្ពន្ធ័ទី៣) សម្រាប់សិក្ខាកាមបំពេញ នៅពេលចុង

បញ្ចប់នៃការចុះអនុវត្តន៍ ដើម្បីប្រមូលមតិកែលម្អអំពីការរៀបចំ ការគ្រប់គ្រង អត្ថប្រយោជន៍នៃការអនុវត្តន៍ផ្ទាល់ ក៏ដូចជាគំនិតផ្សេងៗរបស់សិក្ខាកាមបានរៀនសូត្រពេលអនុវត្តផ្ទាល់។

- ទម្រង់តាមដានបញ្ចប់នៃវគ្គបណ្តុះបណ្តាល(ឧបសម្ព័ន្ធទី៨) សម្រាប់ធ្វើឡើងនៅពេលបញ្ចប់គឺថ្ងៃចុងក្រោយនៃវគ្គ ដើម្បីប្រមូលមតិកែលម្អ និងសម្រាប់វាស់វែងលើបទពិសោធន៍រៀនសូត្ររបស់សិក្ខាកាមដោយប្រើវិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម។
- ឯកសារនេះ ក៏រួមមានផងដែរនូវ ឧបករណ៍សម្រាប់វាយតម្លៃអាហារូបត្ថម្ភ ទម្រង់តាមដានអត្ថបទសម្រាប់ដើរតួសម្តែង ដែលអាចអនុវត្តក្នុងពេលបណ្តុះបណ្តាល។

ប៉ុន្មានថ្ងៃមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល អ្នកសម្របសម្រួលចាំបាច់គួរធ្វើការរៀបចំដូចខាងក្រោម៖

1. ពិនិត្យ និងរៀបចំសម្ភារៈដែលត្រូវការប្រើសម្រាប់មេរៀននីមួយៗ ដូចជា៖ ក្រដាសធំ ហ្វឺតសរសេរស្កុត ក្រដាសA៤ បាល់ គ្រាប់សណ្តែក ផ្ទាំងរូបភាព ម៉ែត្រវាស់...។ល។
2. ថតចម្លងទម្រង់វាយតម្លៃប្រចាំថ្ងៃឱ្យបានគ្រប់ចំនួនសម្រាប់សិក្ខាកាមទាំងអស់
3. បោះពុម្ពវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាសម្រាប់សិក្ខាកាម ដោយមានចុះហត្ថលេខាបើចាំបាច់
4. សរសេរគោលបំណងមេរៀននីមួយៗ នៅលើក្រដាសផ្ទាំងធំ មុនពេលវគ្គបណ្តុះបណ្តាល ទុកសម្រាប់បង្ហាញនៅពេលចាប់ផ្តើមមេរៀន
5. អាន និងសិក្សានូវផែនការបង្រៀនដោយហ្មត់ចត់ ដើម្បីយល់ច្បាស់ និងអាចដឹកនាំសកម្មភាពក្នុងវគ្គ។ រៀបចំកំណត់ត្រាខ្លីៗសម្រាប់ខ្លួនឯង ដើម្បីចងចាំជំហានសំខាន់ៗ ឬចំនុចដែលត្រូវនិយាយ។
6. រៀបចំបន្ទប់រៀន ដោយរៀបកៅអីជារាងជាអក្សរ U ឬជារង្វង់ ដែលអាចឱ្យសិក្ខាកាមមើលឃើញគ្នា ដើម្បីជំរុញការពិភាក្សា។ ព្យាយាមចៀសវាងការអង្គុយជាជួរ បែរមុខទៅរកទិសតែមួយ
7. រៀបចំ អាហារ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់សិក្ខាកាម
8. រៀបចំកិច្ចការរដ្ឋបាលផ្សេងៗ (សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភ បញ្ជីវត្តមាន ...។ល។)
9. រៀបចំសម្រាប់"ការចុះអនុវត្តន៍នៅមូលដ្ឋាន" ដែលនឹងត្រូវធ្វើនៅថ្ងៃចុងក្រោយនៃវគ្គ។ គិតមើលថាតើនឹងចុះទៅភូមិណា? អ្នករស់នៅជាមួយមេរោគអេដស៍ណាដែលអ្នកចង់ជួប? សូមផ្តល់ព័ត៌មានអំពីពេលវេលា និងគោលបំណងរបស់អ្នក ដល់សហគមន៍ដែលអ្នកនឹងចុះទៅ។ ផ្តល់ឱកាសឱ្យសិក្ខាកាមគ្រប់អនុវត្តជំនាញដែលគេបានរៀន។

## កាលវិភាគសម្រាប់ការបណ្តុះបណ្តាល (អនុសាសន៍)

កម្មវិធីបណ្តុះបណ្តាលរយៈពេល៥ថ្ងៃនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ព័ត៌មានដែលចាំបាច់សម្រាប់អ្នកផ្តល់ប្រឹក្សា ដើម្បីផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ ការថែទាំសុខភាព និងការគាំទ្រឱ្យមានប្រសិទ្ធភាពដល់អ្នករស់នៅជាមួយមេរោគអេដស៍។ ខាងក្រោមនេះជាកាលវិភាគជាអនុសាសន៍ សម្រាប់ការបណ្តុះបណ្តាល៖

- ថ្ងៃទី ១៖ មេរៀនទី១ ទី២ និងទី៣
- ថ្ងៃទី ២៖ មេរៀនទី៣ និងទី៤
- ថ្ងៃទី ៣៖ មេរៀនទី៥
- ថ្ងៃទី ៤៖ មេរៀនទី៦ និងការរៀបចំចុះអនុវត្តន៍នៅមូលដ្ឋាន
- ថ្ងៃទី ៥៖ ចាត់ចែងការចុះអនុវត្តន៍នៅមូលដ្ឋាន(ព្រឹក) សង្ខេប និងចែកវិញ្ញាបនប័ត្រ (រសៀល)

សូមឱ្យមានពេលវេលាគ្រប់គ្រាន់នៅក្នុងវគ្គបណ្តុះបណ្តាលដើម្បីប្រើឱ្យអស់នូវសម្ភារៈទាំងអស់។ កុំប្រញាប់ប្រញាល់។ ប្រសិនបើមិនអាចផ្តល់វគ្គបណ្តុះបណ្តាលក្នុងរយៈពេល៥ថ្ងៃជាប់គ្នាទេ អ្នកអាចពិចារណាបែងចែកជា៣វគ្គដែលមានរយៈពេល២ថ្ងៃក្នុងមួយវគ្គ។

## កាលវិភាគសម្រាប់វគ្គបណ្តុះបណ្តាល

| ថ្ងៃទី១ | | |
|---|---|---|
| **ម៉ោង** | **រយៈពេល** | **មេរៀន** |
| ៨.០០-៨.៤០ | ៤០ នាទី | កម្មវិធីបើកវគ្គ (បើកកម្មវិធី ទិដ្ឋភាពទូទៅ និងល្បែងថាមពល) |
| ៨.៤០-៩.០០ | ២០ នាទី | សំណួរសាកល្បងមុនពេលរៀន |
| ៩.០០-៩.៣០ | ៣០ នាទី | មេរៀនទី១៖ សេចក្តីផ្តើមនៃកញ្ចប់សម្ភារៈអាហារល្អ–គោលបំណងរបស់កញ្ចប់សម្ភារៈអាហាល្អ |
| ៩.៣០-៩.៤៥ | ១៥ នាទី | សម្រាក |
| ៩.៤៥ -១០.០០ | ១៥ នាទី | មេរៀនទី១៖ សេចក្តីផ្តើមនៃកញ្ចប់សម្ភារៈអាហារល្អ–ក្រុមគោលដៅ និងក្រុមគោលដៅចំបងសម្រាប់ប្រឹក្សាផ្នែកអាហារូបត្ថម្ភ |
| ១០.០០-១០.១៥ | ១៥ នាទី | មេរៀនទី១៖ សេចក្តីផ្តើមនៃកញ្ចប់សម្ភារៈអាហារល្អ ខ្លឹមសាររបស់កញ្ចប់សម្ភារៈអាហារល្អ |
| ១០.១៥-១០.៣០ | ១៥ នាទី | មេរៀនទី២៖ មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ ពាក្យមូលដ្ឋានសំខាន់ៗរបស់អាហារូបត្ថម្ភ |
| ១០.៣០-១១.៣០ | ៦០ នាទី | មេរៀនទី២៖មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ– អាហារទាំង៣ក្រុម |
| ១១.៣០-១៣.៣០ | ១២០ នាទី | សម្រាកអាហារថ្ងៃត្រង់ |
| ១៣.៣០-១៤.០០ | ៣០ នាទី | មេរៀនទី២៖ មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ– តម្រូវការថាមពល |
| ១៤.០០-១៥.០០ | ៦០ នាទី | មេរៀនទី២៖ មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ–អាហារូបត្ថម្ភក្នុងវដ្តជីវិត |
| ១៥.០០-១៥.១៥ | ១៥ នាទី | សម្រាក |
| ១៥.១៥-១៦.០០ | ៤៥ នាទី | មេរៀនទី២៖ មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ–អាហារូបត្ថម្ភក្នុងវដ្តជីវិត |
| ១៦.០០-១៦.៣០ | ៣០ នាទី | មេរៀនទី៣៖ អាហារូបត្ថម្ភ និងមេរោគអេដស៍–ទំនាក់ទំនងរវាងមេរោគអេដស៍ និងអាហារូបត្ថម្ភ |
| ១៦.៣០-១៧.០០ | ៣០ នាទី | សរុបប្រចាំថ្ងៃ និងការវាយតម្លៃវគ្គប្រចាំថ្ងៃ |
| ១៧.០០ | | ចប់ថ្ងៃទី១ |

| ថ្ងៃទី២ | | |
|---|---|---|
| **ម៉ោង** | **រយៈពេល** | **មេរៀន** |
| ៨.០០-៨.១៥ | ១៥ នាទី | រំលឹកមេរៀនថ្ងៃទី១ |
| ៨.១៥-៨.៤៥ | ៣០ នាទី | មេរៀនទី៣៖ អាហារូបត្ថម្ភ និងមេរោគអេដស៍– តម្រូវការថាមពល និងកំណើនភាគរយសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ |
| ៨.៤៥-៩.៣០ | ៤៥ នាទី | មេរៀនទី៣៖ អាហារូបត្ថម្ភ និងមេរោគអេដស៍– វដ្តនៃជំងឺអេដស៍ ភាពចុះខ្សោយនៃអាហារូបត្ថម្ភ និងការឆ្លងជំងឺ |
| ៩.៣០-៩.៤៥ | ១៥ នាទី | សម្រាក |
| ៩.៤៥-១០.៣០ | ៤៥ នាទី | មេរៀនទី៣៖ អាហារូបត្ថម្ភ និងមេរោគអេដស៍– ព័ត៌មានមិនពិតអំពីអាហារូបត្ថម្ភ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ |
| ១០.៣០-១១.៣០ | ៦០ នាទី | មេរៀនទី៤៖ មនុស្សមាត្រវិធី– ការប៉ាន់វាយតម្លៃបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់មនុស្សពេញវ័យ |
| ១១.៣០-១៣.៣០ | ១២០ នាទី | អាហារថ្ងៃត្រង់ |
| ១៣.៣០-១៥.០០ | ៩០ នាទី | មេរៀនទី៤៖ មនុស្សមាត្រវិធី– ការវាយតម្លៃបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់កុមារ |
| ១៥.០០-១៥.១៥ | ១៥ នាទី | សម្រាក |
| ១៥.១៥-១៦.៣០ | ៧៥ នាទី | មេរៀនទី៤៖ មនុស្សមាត្រវិធី– ការវាយតម្លៃបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់កុមារ |
| ១៦.៣០-១៧.០០ | ៣០ នាទី | សរុបប្រចាំថ្ងៃ និងការវាយតម្លៃវគ្គប្រចាំថ្ងៃ |
| ១៧.០០ | | ចប់ថ្ងៃទី២ |

| ថ្ងៃទី៣ | | |
|---|---|---|
| **ម៉ោង** | **រយៈពេល** | **មេរៀន** |
| ៨.០០-៨.១៥ | ១៥ នាទី | រំលឹកមេរៀនថ្ងៃទី២ |
| ៨.១៥-៩.៣០ | ៧៥ នាទី | មេរៀនទី៥៖ របៀបប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ– ជំហានទាំង៥នៃការផ្តល់ប្រឹក្សា |
| ៩.៣០-៩.៤៥ | ១៥ នាទី | សម្រាក |
| ៩.៤៥-១១.០០ | ៧៥ នាទី | មេរៀនទី៥៖ របៀបប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ– ការប្រើប្រាស់ប័ណ្ណអាហារតូច |
| ១១.០០-១១.៣០ | ៣០ នាទី | មេរៀនទី៥៖ របៀបប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ– ការប្រើប្រាស់ប័ណ្ណអាហារធំ |

| ថ្ងៃទី៣ | | |
|---|---|---|
| ១១.៣០-១៣.៣០ | ១២០ នាទី | អាហារថ្ងៃត្រង់ |
| ១៣.៣០-១៣.៤០ | ១០ នាទី | ល្បែងថាមពល |
| ១៣.៤០-១៥.០០ | ៨០ នាទី | មេរៀនទី៥៖ របៀបប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ– ការបំពេញទម្រង់តាមដាន |
| ១៥.០០-១៥.១៥ | ១៥ នាទី | សម្រាក |
| ១៥.១៥-១៦.៣០ | ៧៥ នាទី | មេរៀនទី៥៖ របៀបប្រើប្រាស់កញ្ចប់សម្ភារៈអាហារល្អ– ការបំពេញទម្រង់តាមដាន |
| ១៦.៣០-១៧.០០ | ៣០ នាទី | សរុបប្រចាំថ្ងៃ និងការវាយតំលៃប្រចាំថ្ងៃ |
| ១៧.០០ | | ចប់ថ្ងៃទី៣ |

| ថ្ងៃទី៤ | | |
|---|---|---|
| **ម៉ោង** | **រយៈពេល** | **មេរៀន** |
| ៨.០០-៨.១៥ | ១៥ នាទី | រំលឹកមេរៀនថ្ងៃទី៣ |
| ៨.១៥-៩.៣០ | ៧៥ នាទី | មេរៀនទី៦៖ ការរស់នៅប្រកបដោយសុខភាពល្អសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍– ប័ណ្ណរស់នៅប្រកបដោយសុខភាពល្អ |
| ៩.៣០-៩.៤៥ | ១៥ នាទី | សម្រាក |
| ៩.៤៥-១១.៣០ | ១០៥ នាទី | មេរៀនទី៦៖ ការរស់នៅប្រកបដោយសុខភាពល្អ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍– ប័ណ្ណរស់នៅប្រកបដោយសុខភាពល្អ |
| ១១.៣០-១៣.៣០ | ១២០ នាទី | អាហារថ្ងៃត្រង់ |
| ១៣.៣០-១៣.៤០ | ១០ នាទី | ល្បែងថាមពល |
| ១៣.៤០-១៥.០០ | ៨០ នាទី | មេរៀនទី៦៖ ការរស់នៅប្រកបដោយសុខភាពល្អ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍– មូលដ្ឋានគ្រឹះនៃជំនាញក្នុងការប្រាស្រ័យទាក់ទង |
| ១៥.០០-១៥.១៥ | ១៥ នាទី | សម្រាក |
| ១៥.១៥-១៦.១៥ | ៦០ នាទី | រៀបចំសម្រាប់ការចុះអនុវត្តន៍នៅមូលដ្ឋាន |
| ១៦.១៥-១៦.៣៥ | ២០ នាទី | សំណួរសាកល្បងក្រោយមេរៀន |
| ១៦.៣៥-១៧.០០ | ២៥ នាទី | សរុបប្រចាំថ្ងៃ |
| ១៧.០០ | | ចប់ថ្ងៃទី៤ |

| ថ្ងៃទី៥ | | |
|---|---|---|
| **ម៉ោង** | **រយៈពេល** | **មេរៀន** |
| ៨.០០-១១.៣០ | ២១០ នាទី | ការអនុវត្តន៍នៅមូលដ្ឋាន |
| ១១.៣០-១៣.៣០ | ១២០ នាទី | សម្រាកអាហារថ្ងៃត្រង់ |
| ១៣.៣០-១៤.៣០ | ៦០ នាទី | សំណួរពាក់ព័ន្ធនឹងការអនុវត្តន៍នៅមូលដ្ឋាន |
| ១៤.៣០-១៥.០០ | ៤០ នាទី | វាយតម្លៃវគ្គបណ្តុះបណ្តាល និងការអនុវត្តន៍ផ្ទាល់នៅមូលដ្ឋាន |
| ១៥.០០-១៥.១៥ | ១៥ នាទី | សម្រាក |
| ១៥.១៥-១៦.០០ | ៤៥ នាទី | កម្មវិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា |
| ១៦.០០-១៧.០០ | ៦០ នាទី | សរុប និងបិទកម្មវិធី |
| ១៧.០០ | | ចប់វគ្គបណ្តុះបណ្តាល |

## ការបណ្តុះបណ្តាលគ្រូបង្គោល

មេរៀនសម្រាប់បណ្តុះបណ្តាលនេះគួរតែប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាលគ្រប់កម្រិតរួមទាំងការបណ្តុះបណ្តាលគ្រូបង្គោល។ វិធីសាស្ត្រ និងសកម្មភាពផ្សេងៗដែលបានប្រើក្នុងវគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិកសេវាសុខភាពកម្រិតមូលដ្ឋាន នៅតាមសហគមន៍ និងផ្ទះរបស់អ្នករស់នៅជាមួយមេរោគអេដស៍។ សកម្មភាពភាគច្រើនទាក់ទងនឹងការធ្វើបទបង្ហាញមេរៀនតាមរយៈការស្តាប់ ការមើល ការធ្វើបទបង្ហាញខ្លីៗ ការពិភាក្សារូបភាព ការធ្វើបង្ហាញ ល្បែង ការសម្តែងតួ និងលំហាត់អនុវត្តន៍។

ការបណ្តុះបណ្តាលគ្រូបង្គោលគួរធ្វើនៅដំណាក់កាលទីពីរ។ ក្នុងដំណាក់កាលទីមួយសិក្ខាកាមនឹងទទួលបានការបណ្តុះបណ្តាលរយៈពេល៥ថ្ងៃពេញ។ សិក្ខាកាមដែលជាអនាគតគ្រូបង្គោលក៏គួរតែឆ្លងកាត់នូវសកម្មភាពបណ្តុះបណ្តាលដូចគ្នាដែរ។ ត្រូវទុកពេលវេលាឱ្យសិក្ខាកាមបានអនុវត្តន៍នូវអ្វីដែលពួកគេបានរៀនក្នុងរយៈពេល៥ថ្ងៃ។ សិក្ខាកាមគួរចាំបាច់អនុវត្តន៍ផ្ទាល់ឱ្យបានយ៉ាងតិច៦ខែ បន្ទាប់ពីការបណ្តុះបណ្តាលលើកទី១ មុនពេលទទួលយកការបណ្តុះបណ្តាលបន្ទាប់។

ក្នុងដំណាក់កាលទីពីរ សិក្ខាកាមនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមដើម្បីធានាថាពួកគេមានជំនាញ និងទំនុកចិត្តលើសមត្ថភាពខ្លួនឯង ក្នុងការបណ្តុះបណ្តាល និងផ្តល់ព័ត៌មានដល់អ្នកផ្សេងៗទៀត។ ការបណ្តុះបណ្តាលកម្រិតនេះផ្តល់ឱកាសជាច្រើនដល់សិក្ខាកាមដែលជាអនាគតគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលគ្នាទៅវិញទៅមក ដោយអនុវត្តន៍នូវអ្វីដែលពួកគេបានរៀន។

## គម្រោងមេរៀនទី១

*គោលបំណងមេរៀន*

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចរៀបរាប់អំពី៖

1. គោលបំណងនៃកញ្ចប់សម្ភារៈអាហារល្អ
2. ក្រុមគោលដៅត្រឹមត្រូវសម្រាប់ការធ្វើការប្រឹក្សាអំពីអាហារូបត្ថម្ភដោយប្រើប្រាស់កញ្ចប់សម្ភារៈនេះ
3. សមាសភាពចម្បងៗដែលមាននៅក្នុងកញ្ចប់សម្ភារៈអាហារល្អ

*មាតិកា*

- ប្រវត្តិរបស់ "កញ្ចប់សម្ភារៈអាហារល្អ"
- គោលបំណងនៃការប្រើ "កញ្ចប់សម្ភារៈអាហារល្អ"
- ក្រុមគោលដៅនៃ "កញ្ចប់សម្ភារៈអាហារល្អ"
- ខ្លឹមសារនៃ "កញ្ចប់សម្ភារៈអាហារល្អ"
- សំណួរសាកល្បង

*វិធីសាស្ត្របង្រៀន*

- ការបំផុសគំនិត
- ការធ្វើបង្ហាញ
- ការពិភាក្សាក្រុម និង
- ការធ្វើបទបង្ហាញរបស់សិក្ខាកាម

*សម្ភារៈជំនួយបង្រៀន*

- "កញ្ចប់សម្ភារៈអាហារល្អ"
- ច្បាប់ចម្លងនៃកូនសៀវភៅស្តីពី "ការថែទាំខ្លួនឯង" របស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI)
- ច្បាប់ចម្លងនៃឯកសារជំនួយសម្រាប់ការបណ្តុះបណ្តាលស្តីពី "អាហារូបត្ថម្ភ និងមេរោគអេដស៍ របស់អង្គការខាណា (KHANA)"
- ច្បាប់ចម្លងនៃសៀវភៅស្តីពី "ការចិញ្ចឹមបីបាច់បន្ថែមសម្រាប់ក្មេងអាយុពី៦ទៅ២៣ខែ" របស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO)
- ច្បាប់ចម្លងនៃសៀវភៅផ្ទាំងរូបភាពស្តីពី "ការលើកកម្ពស់ ការគាំទ្រការចញ្ចឹម និងថែទាំទារក និងកុមារតូចៗនៅក្នុងសហគមន៍ស្រឡាញ់ទារក (BFCI)" របស់កម្មវិធីជាតិអាហារូបត្ថម្ភ
- ច្បាប់ចម្លងស្តីពី "ឯកសារជំនួយបង្ហាញការដាំស្ល"
- ក្រដាសផ្ទាំងធំ ឬក្តារខៀន
- ហ្វឺតសម្រាប់សរសេរ
- ស្ទីកគ័រពណ៌

*រយៈពេល៖ ១ ម៉ោង*

*ការវាយតម្លៃ៖ សំណួរសាកល្បង*

## គម្រោងមេរៀនទី២

### គោលបំណងមេរៀន

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចៈ

1. កំណត់និយមន័យពាក្យគន្លឹះទាក់ទងនឹងមូលដ្ឋាននៃអាហារូបត្ថម្ភ
2. ប្រាប់ឈ្មោះក្រុមអាហារទាំងបីក្រុមដោយរៀបរាប់ពីតួនាទីរបស់ក្រុមអាហារនីមួយៗ នៅក្នុងរាងកាយ និងផ្តល់ឧទាហរណ៍ដែលមាននៅក្នុងអាហារក្រុមនីមួយៗ
3. អាចរៀបរាប់បានថា "តើថាមពលជាអ្វី" និងរៀបរាប់ពីតម្រូវការថាមពលសម្រាប់ក្រុមមនុស្សផ្សេងគ្នា
4. យល់អំពីការផ្លាស់ប្តូរនៃតម្រូវការអាហារូបត្ថម្ភក្នុងវដ្តជីវិតរបស់មនុស្ស

### មាតិកា

- មូលដ្ឋាននៃអាហារូបត្ថម្ភ
- អាហារទាំងបីក្រុម
- អាចរៀបរាប់បានថា "តើថាមពលជាអ្វី?"
- យល់អំពីការផ្លាស់ប្តូរនៃតម្រូវការអាហារូបត្ថម្ភក្នុងវដ្តជីវិតរបស់មនុស្ស
- ការចិញ្ចឹមទារក

### វិធីសាស្ត្របង្រៀន

- ការធ្វើបទបង្ហាញដោយមានការចូលរួម
- ការបំផុសគំនិត
- ពិភាក្សាក្រុម
- ល្បែង

### សម្ភារៈជំនួយបង្រៀន

- "កញ្ចប់សម្ភារៈអាហារល្អ"
- ផ្ទាំងរូបភាពអំពីអាហារទាំងបីក្រុមរបស់អង្គការ ហេឡែនខេលល័រអន្តរជាតិ/កម្មវិធីជាតិអាហារូបត្ថម្ភ
- ក្រដាសផ្ទាំងធំ ឬក្តារខៀនសម្រាប់សរសេរហ្វឺត
- ហ្វឺតសម្រាប់សរសេរ
- កូនបាល់
- រូបភាពបាយក្នុងចានយកចេញពីកញ្ចប់សម្ភារៈ
- រូបភាពដើមស្រូវដែលលូតលាស់ល្អ (ខ្ពស់) និងលូតលាស់មិនល្អ (ទាប)
- បង់ស្អិត ឬម្ជុល

### រយៈពេលៈ ៣ ម៉ោងកន្លះ

### ការវាយតម្លៃៈ សំណួរសាកល្បង

## គម្រោងមេរៀនទី៣

### *គោលបំណងមេរៀន*

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាច៖

1. យល់អំពីទំនាក់ទំនងរវាងមេរោគអេដស៍ និងអាហារូបត្ថម្ភ
2. រៀបរាប់ពីវដ្តនៃមេរោគអេដស៍ បញ្ហាកង្វះអាហារូបត្ថម្ភ និងការឆ្លងរោគ
3. ពិភាក្សាអំពីកត្តារារាំងក្នុងការទទួលបានអាហារូបត្ថម្ភល្អ
4. ពិភាក្សាពីវិធី៧យ៉ាងដើម្បីបង្កើន ឬរក្សាទម្ងន់ប្រកបដោយសុខភាពល្អ (មនុស្សពេញវ័យ និងកុមារ) ឬដើម្បីរក្សាឱ្យមានការលូតលាស់ល្អ (កុមារ)
5. យល់ដឹងអំពីព័ត៌មានមិនត្រឹមត្រូវអំពីមេរោគអេដស៍ និងអាហារ និងផ្តល់ព័ត៌មានត្រឹមត្រូវ

### *មាតិកា*

- ទំនាក់ទំនងរវាងមេរោគអេដស៍ អាហារូបត្ថម្ភ និងការឆ្លងរោគ
- ថាមពលបន្ថែមដែលជាតម្រូវការទាមទាររបស់អ្នករស់នៅជាមួយមេរោគអេដស៍
- ឱសថប្រឆាំងនឹងមេរោគអេដស៍ និងអាហារូបត្ថម្ភ
- របៀបថែរក្សាទម្ងន់ (មនុស្សពេញវ័យ) ឬរក្សាការលូតលាស់ល្អ (កុមារ) ឬដើម្បីបង្កើន និងរក្សាទម្ងន់ឱ្យនៅធម្មតា (មនុស្សពេញវ័យ និងកុមារ)
- ការយល់ខុសអំពីអាហារូបត្ថម្ភ និងព័ត៌មានដែលត្រឹមត្រូវពិត

### *វិធីសាស្ត្របង្រៀន*

- ដោយមានការចូលរួម
- ការបំផុសគំនិត
- បទបង្ហាញ
- ល្បែង
- ការពិភាក្សាក្រុមតូចៗ
- ការពិភាក្សាដោយចំហក្នុងក្រុមធំ

### *សម្ភារៈជំនួយបង្រៀន*

- គោលបំណងមេរៀនដែលបានសរសេរលើក្រដាសផ្ទាំងធំ
- បណ្ណ័ពណ៌ស្វាយបង្ហាញពីគ្រឿងផ្សំដែលជួយបង្កើនថាមពលមកពីកញ្ចប់សម្ភារៈ
- រូបភាពចានសម្លមកពីកញ្ចប់សម្ភារៈ និងឯកសារសម្រាប់បណ្តុះបណ្តាល
- រូបភាពបាយពីកញ្ចប់សម្ភារៈ
- ក្រដាសផ្ទាំងធំ ក្រដាសតូច បង់ស្អិត និងហ្វឺត

### *រយៈពេល៖ ២ ម៉ោងកន្លះ*

### *ការវាយតម្លៃ៖ សំណួរសាកល្បង*

## គម្រោងមេរៀនទី៤

*គោលបំណងមេរៀន*

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចៈ

1. ប្រាប់ពីវិធី ៣យ៉ាងក្នុងការប៉ាន់ប្រមាណកម្រិតអាហារូបត្ថម្ភរបស់មនុស្សពេញវ័យ និងកុមារ
2. វាស់ និងកត់ត្រាបានត្រឹមត្រូវនូវកម្ពស់ និងទម្ងន់របស់មនុស្សពេញវ័យ
3. គណនាសន្ទស្សន៍ម៉ាស់រាងកាយ(BMI) ដោយប្រើកម្ពស់ និងទម្ងន់របស់មនុស្សពេញវ័យ
4. វាស់ កត់ត្រា និងបកស្រាយរង្វាស់ពាក់កណ្តាលដើមដៃស្ត្រីមានផ្ទៃពោះ ឬទើបសម្រាលកូនរួចក្នុងអំឡុង៦ខែ និងកុមារអាយុពី ៦-៥៩ខែ
5. វាស់ និងបកស្រាយប្រវែង កម្ពស់ និងទម្ងន់កុមារអាយុចាប់ពី ៦-៥៩ ខែ និងសន្ទស្សន៍ម៉ាស់រាងកាយតាមអាយុរបស់កុមារអាយុចាប់ពី ៥-១៩ ឆ្នាំ

*មាតិកា*

- ហេតុអ្វីបានជាត្រូវវាយតម្លៃកម្រិតអាហារូបត្ថម្ភរបស់អ្នករស់នៅជាមួយមេរោគអេដស៍?
- បញ្ហាកង្វះអាហារូបត្ថម្ភរបស់អ្នករស់នៅជាមួយមេរោគអេដស៍
- វិធីប៉ាន់ប្រមាណបញ្ហាកង្វះអាហារូបត្ថម្ភរបស់អ្នករស់នៅជាមួយមេរោគអេដស៍
- ការវាស់មនុស្សពេញវ័យ
- ការវាស់កុមារ និងក្មេងជំទង់

*វិធីសាស្ត្របង្រៀន*

- បទបង្ហាញ
- ការធ្វើបង្ហាញ
- ការអនុវត្តន៍ផ្ទាល់

*សម្ភារៈជំនួយបង្រៀន*

- គោលបំណងមេរៀនដែលបានសរសេរលើក្រដាសផ្ទាំងធំ
- សៀវភៅគ្របរឹង ឬក្តារតម្បៀតខ្ទាស់ ទំហំប៉ុនគ្នា (មួយសម្រាប់មួយក្រុម)
- តារាងទម្ងន់គំរូ របស់មន្ទីរព្យាបាលជំងឺឱកាសនិយម/ព្យាបាលដោយប្រើឱសថប្រឆាំងមេរោគអេសដ៍
- តារាងសន្ទស្សន៍ម៉ាស់រាងកាយសម្រាប់មនុស្សពេញវ័យ (មួយសម្រាប់សិក្ខាកាមម្នាក់)
- តារាងសន្ទស្សន៍ម៉ាស់រាងកាយកុមារ និងក្មេងជំទង់
- ម៉ាស៊ីនគិតលេខ
- បង់ស្អិត ក្រដាសផ្ទាំងធំ ប៊ិច ឬហ្វឺតដែលមានចុងតូច ហ្វឺតពណ៌ ប៊ិចសេរសេរ និងប៊ិចចុងធំ
- ម៉ែត្រវាស់ (ស.ម) (ម៉ែត្រ១សម្រាប់សិក្ខាកាមមួយក្រុមតូច)
- រង្វាស់ពាក់កណ្តាលដើមដៃសម្រាប់កុមារអាយុ៦–៥៩ខែ
- ម៉ែត្ររង្វាស់ពាក់កណ្តាលដើមដៃសម្រាប់មនុស្សពេញវ័យ
- ក្តាររង្វាស់កម្ពស់ និងទម្ងន់
- ជញ្ជីងយូនីស្កេល
- ជញ្ជីងថ្លឹងទារក
- កំណត់ត្រាសុខភាពរបស់អង្គការសុខភាពពិភពលោក
- ទារកជ័រសម្រាប់ការហាត់វាស់ ឬអ្នកក្នុងភូមិដែលអាចឱ្យសិក្ខាកាមហាត់វាស់បាន (បើសមស្រប)

*រយៈពេលៈ ៣ម៉ោង ៤៥នាទី*

*ការវាយតម្លៃៈ សំណួរសាកល្បង*

## គម្រោងមេរៀនទី៥

*គោលបំណងមេរៀន*

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចៈ

1. ធ្វើបទបង្ហាញពីជំហានទាំង៥សម្រាប់ការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ
2. បំពេញទម្រង់តាមដានកញ្ចប់សម្ភារៈ

*មាតិកា*

- ខ្លឹមសារកញ្ចប់សម្ភារៈអាហារល្អ
- ជំហានទាំង៥សម្រាប់ការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ
- អនុវត្តន៍ទ្រឹស្តីៈ ការសំដែងតួ

*វិធីសាស្រ្តបង្រៀន*

- រំលឹកមេរៀន
- បទបង្ហាញ
- ការធ្វើបង្ហាញ
- លំហាត់អនុវត្តន៍ផ្ទាល់

*សម្ភារៈជំនួយបង្រៀន*

- កញ្ចប់សម្ភារៈអាហារល្អ (សិក្ខាកាមម្នាក់មួយច្បាប់)
- គោលបំណងមេរៀនដែលបានសរសេរលើក្រដាសផ្ទាំងធំ
- ទម្រង់តាមដានការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ (៣ច្បាប់សម្រាប់សិក្ខាកាមម្នាក់ៗ)
- ទម្រង់តាមដានសរសេរនៅលើក្រដាសផ្ទាំងធំ២សន្លឹក ឬលើក្តារខៀន ឬឧបករណ៍បញ្ចាំងស្លាយ
- ជំហាននៃការផ្តល់ប្រឹក្សាស្តីពីអាហារូបត្ថម្ភនៅលើក្រដាសផ្ទាំងធំ ឬក្តារខៀន
- រូបផ្កាយធ្វើពីក្រដាសពណ៌
- ហ្វឺតសរសេរ
- បង់ស្អិត

*រយៈពេលៈ ៥ម៉ោង ៣៥នាទី*

*ការវាយតម្លៃៈ សំណួរសាកល្បង*

## គម្រោងមេរៀនទី៦

*គោលបំណងមេរៀន*

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចៈ

1. រៀបរាប់ពីសារៈសំខាន់នៃការអនុវត្តការរស់នៅប្រកបដោយសុខភាពល្អ ដើម្បីរក្សាទម្ងន់ និងសុខភាពឱ្យបានល្អ
2. រៀបរាប់អំពីរបបអាហារ និងវិធីសាស្ត្រគ្រប់គ្រងរោគសញ្ញាមេរោគអេដស៍
3. ស្វែងយល់អំពីជំនាញនៃការទំនាក់ទំនងល្អ និងពីរបៀបប្រើជំនាញនេះក្នុងការប្រឹក្សាយោបល់
4. ប្រើប័ណ្ណរស់នៅប្រកបដោយសុខភាពល្អដើម្បីប្រឹក្សាយោបល់ជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ និងរបៀបរស់នៅស្អាតដើម្បីបង្ការជំងឺ
5. ប្រើប័ណ្ណរស់នៅប្រកបដោយសុខភាពល្អដែលសមស្របសម្រាប់ប្រឹក្សាយោបល់ជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ ទៅតាមស្ថានភាពជាក់ស្តែងរបស់គាត់។

*មាតិកា*

- ការរស់នៅប្រកបដោយសុខភាពល្អសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍
- របបអាហារ និងវិធីសាស្ត្រផ្សេងៗ ដើម្បីគ្រប់គ្រងរោគសញ្ញាមេរោគអេដស៍
- ការប្រឹក្សាយោបល់ជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ អំពីការរស់នៅប្រកបដោយសុខភាពល្អ
- ជំនាញទំនាក់ទំនងល្អ

*វិធីសាស្ត្របង្រៀន*

- ការធ្វើបង្ហាញ
- ការធ្វើបទបង្ហាញ
- ការពិភាក្សា ល្បែង និងការសម្តែងតួ

*សម្ភារៈជំនួយបង្រៀន*

- គោលបំណងមេរៀនដែលបានសរសេរលើក្រដាសផ្ទាំងធំ
- ក្រដាសផ្ទាំងធំ ឬក្តារខៀន និងហ្វឺតសម្រាប់សរសេរ
- ក្រដាសរ៉ាមទំហំA៤ ប៊ិច និងខ្មៅដៃសម្រាប់សិក្ខាកាមម្នាក់
- ទម្រង់តាមដានសរសេរលើក្រដាសផ្ទាំងធំ(ដូចក្នុងមេរៀនទី៥)
- ថង់សណ្តែក(យ៉ាងតិចត្រូវមានសណ្តែក១៥គ្រាប់សម្រាប់សិក្ខាកាមម្នាក់ )
- រង្វាន់សម្រាប់អ្នកឈ្នះល្បែងបើអាចបង្ហាញពីរបៀបលាងដៃទឹកស្អាត (ឬធុងទឹក និងការដងទឹក)
- សាប៊ូដុំ ឬផេះ

*រយៈពេលៈ ៤ ម៉ោង ២០នាទី*

*ការវាយតម្លៃៈ សំណួរសាកល្បង*